Open Development Cambodia
www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 224 782
contact@opendevcam.net

# សិក្ខាសាលា ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
# ស្តីពី៖ មូលដ្ឋានគ្រឹះនៃ QGIS

## សេចក្តីផ្តើម

អង្គការទិន្នន័យអំពីការអភិវឌ្ឍ ហៅកាត់ថាអូឌីស៊ី គឺជាគេហទំព័របែប "ទិន្នន័យបើកទូលាយ"។ គេហទំព័រប្រភេទនេះ ជាគេហទំព័រដំបូងគេបង្អស់នៅតំបន់អាស៊ីអាគ្នេយ៍។ ចលនា "ទិន្នន័យបើកទូលាយ" គឺផ្អែកលើការសន្មត់ដ៏សាមញ្ញមួយថា ទិន្នន័យ ឬព័ត៌មានទាំងឡាយណា ដែលត្រូវបានប្រមូលផ្តុំសម្រាប់ផលប្រយោជន៍សាធារណៈ គួរតែដាក់ឱ្យប្រើប្រាស់បានជាសាធារណៈពោលគឺដោយគ្មានការដាក់កំហិតឡើយ។ ព័ត៌មានឬ "ទិន្នន័យ" ទាក់ទងនឹងវិស័យសាធារណៈគួរផ្តល់ឱ្យដោយសេរីដល់គ្រប់ៗគ្នា ដើម្បីប្រើ និងធ្វើការផ្សព្វផ្សាយជាសាធារណៈតាមបំណងប្រាថ្នារបស់អ្នកប្រើប្រាស់។ អង្គការអូឌីស៊ីមិនធ្វើការលើកស្ទួយ ឬផ្សព្វផ្សាយទស្សនៈ របៀបវារៈ ឬការលម្អៀងណាមួយ ក្រៅពីការផ្តល់ព័ត៌មានជាសត្យានុម័តអំពីប្រទេសកម្ពុជា និងការអភិវឌ្ឍរបស់ប្រទេសនោះឡើយ។

អង្គការទិន្នន័យអំពីការអភិវឌ្ឍមានសេចក្តីសោមនស្សរីករាយក្នុងការប្រារព្ធសិក្ខាសាលាចំនួន ៣ អំពីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ក្រោមប្រធានបទ មូលដ្ឋានគ្រឹះនៃ QGIS ដែលមានរយៈពេល ៣ ថ្ងៃនៃសិក្ខាសាលានិមួយៗ។ សិក្ខាសាលានេះមានគោលបំណងផ្តល់ជូន នូវចំណេះដឹងអំពីជីអាយអេស និងការប្រើប្រាស់កម្មវិធី ជីអាយអេសបើកទូលាយ (QGIS)។



អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia

Open Development Cambodia
www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 224 782
contact@opendevcam.net

## សិក្ខាសាលា៖

សិក្ខាសាលារយៈពេល ៣ ថ្ងៃដែលគ្របដណ្ដប់លើទិដ្ឋភាពទាំងបីសំខាន់ៗ នៃជីអាយអេស (Geodatabase, ការវិភាគជាមួយជីអាយអេស និងការបង្ហាញទិន្ន័យផែនទី) ដែលនឹងត្រូវបានបង្ហាញ ពិភាក្សា និងអនុវត្តនៅក្នុងបន្ទប់សិក្សា ជាមួយ QGIS រួមមាន៖

- ជំពូក១ ៖ ការចាប់ផ្តើមដំបូងជាមួយកម្មវិធី QGIS
- ជំពូក២ ៖ វិធីសាស្ត្របង្ហាញទិន្នន័យផែនទី
- ជំពូក៣ ៖ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យផែនទី
- ជំពូក៤ ៖ ការធ្វើដំណើរការ និងការវិភាគទិន្នន័យផែនទី
- ជំពូក៥ ៖ ការអនុវត្តជាក់ស្តែងនៃជីអាយអេស

## អំពីសិក្ខាសាលា

ទីតាំង ៖ ការិយាល័យអង្គការទិន្នន័យអំពីការអភិវឌ្ឍ ភ្នំពេញ
តំណភ្ជាប់៖ https://goo.gl/maps/ovUFZgbFaXz

កាលបរិច្ឆេទ ៖

- ថ្ងៃផុតកំណត់ចុះឈ្មោះ៖ **០៨ ខែមីនា ឆ្នាំ២០១៨**
- ថ្ងៃប្រកាសឈ្មោះបេក្ខជន៖ **០៩ ខែមីនា ឆ្នាំ២០១៨**
- ថ្ងៃធ្វើសិក្ខាសាលា៖ **១២ ដល់ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៨**

ការចូលរួមវិភាគទាន ៖ ១៥ ដុល្លាក្នុងម្នាក់

អត្ថប្រយោជន៍ ៖ សម្ភារៈសិក្សា កម្មវិធី អ៊ិនធើណេត សៀវភៅកំណត់ត្រា វិញ្ញាបនបត្រ អាហារសម្រន់ និងអាហារថ្ងៃត្រង់

សំរាប់ការចុះឈ្មោះ ៖ https://goo.gl/SV2owx

មេរៀនសិក្សា ៖ ភាសាខ្មែរ និងអង់គ្លេស

តម្រូវការ ៖ អ្នកចូលរួមត្រូវមាន កុំព្យូរយួរដៃ ចំណេះដឹងក្នុងការប្រើប្រាស់កុំព្យូទ័រ និងភាសាអង់គ្លេសកំរិតមូលដ្ឋាន (អាចយល់ពីពាក្យ

Open Development Cambodia
www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 224 782
contact@opendevcam.net

អង់គ្លេសទូទៅបាន)

ទំនាក់ទំនង ៖ លោក ផាន់ សុវណ្ណគង្គា
សារអេឡិចត្រូនិក ៖ kongkea@opendevcam.net
លេខទូរស័ព្ទ ៖ ០១០ ៧៥៥ ២៩៥

## សិក្ខាសាលានាពេលក្រោយ

សិក្ខាសាលាលើកទី២៖ (ថ្ងៃទី ២៣ ដល់ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៨)

ជំពូក១ ៖ ការគ្រប់គ្រង់ទិន្នន័យភូមិសាស្ត្រដោយគេហទំព័រ និងទូរស័ព្ទដៃ
ជំពូក២ ៖ ការប្រើប្រាស់ជីអាយអេសក្នុងវិស័យគ្រប់គ្រងធនធានធម្មជាតិ
ជំពូក៣ ៖ ការប្រើប្រាស់ជីអាយអេសក្នុងវិស័យគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ

សិក្ខាសាលាលើកទី៣៖ (ថ្ងៃទី ២៥ ដល់ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៨)

ជំពូក១ ៖ ការប្រើប្រាស់ជីអាយអេសក្នុងវិស័យរៀបចំដីធ្លី
ជំពូក២ ៖ ការរួមបញ្ចូលបច្ចេកវិទ្យាក្នុងវិស័យអប់រំ

### អ្នកបង្រៀន

១. លោក វ៉ាមឿន និមល អ្នកប្រឹក្សារបស់អង្គការអូឌីស៊ី និងអ្នកមានជំនាញក្នុងវិស័យជីអាយអេសក្នុងរយៈពេលជាង ១០ឆ្នាំ។ គាត់បានបង្រៀននៅ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាចាប់តាំងពីឆ្នាំ២០០៥។

២. ក្រុមការងារជីអាយអេសរបស់អង្គការអូឌីស៊ី មានជំនាញផ្នែកជីអាយអេស និងមានបទពិសោធន៍ផ្ទាល់ជាមួយការគ្រប់គ្រង និងវិភាគទិន្នន័យផែនទី ដោយការប្រើប្រាស់កម្មវិធីបើកទូលាយ។